THE SCHOOL DISTRICT OF PHILADELPHIA

**ស្នងការដ្ឋាន**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
ស្នងការ

17 កុម្ភៈ 2021

ជូនចំពោះក្រុមគ្រួសាររបស់មណ្ឌលសិក្សាធិការនៃក្រុង Philadelphia ជាទីរាប់អាន

ខ្ញុំដឹងថាភាគច្រើននៃអ្នកទាំងអស់គ្នាគឺមានសេចក្តីរំភើបរីករាយចំពោះការត្រឡប់ចូលរៀនរបស់សិស្សានុសិស្សរបស់អ្នកដោយផ្ទាល់នៅក្នុងថ្នាក់នៅសប្តាហ៍ក្រោយ។ ប៉ុន្តែ ខ្ញុំសរសេរលិខិតនេះដើម្បីចែករំលែកព័ត៌មានដ៏សោកសៅថាផែនការចាប់ផ្តើមឲ្យសិស្សានុសិស្ស និងបុគ្គលិកត្រឡប់មកកាន់សាលារៀនរបស់យើងវិញបន្តិចម្តងៗដោយសន្សឹមៗ និងដោយសុវត្ថិភាពនោះនឹងត្រូវពន្យាររយៈពេលមួយសប្តាហ៍ ដោយសារតែការសម្រុះសម្រួលដោយភាគីទីបីដែលកំពុងប្រព្រឹត្តិទៅ ដែលត្រូវបានស្នើសុំឲ្យធ្វើឡើងដោយសហព័ន្ធគ្រូបង្រៀននៃទីក្រុង Philadelphia។ **ពេលនេះយើងមានផែនការចាប់ផ្តើមស្វាគមន៍សិស្សានុសិស្សឲ្យត្រឡប់ចូលរៀនវិញនៅថ្ងៃចន្ទទី1 ខែមីនា ចាប់ផ្តើមពីសិស្សានុសិស្សថ្នាក់បុរេមត្តេយ្យកម្រិត2 ដែលគ្រួសាររបស់ពួកគេបានជ្រើសរើសការសិក្សាចម្រុះកាលពីរដូវស្លឹកឈើជ្រុះ។**

ក្នុងនាមជាឪពុកម្តាយ និងអាណាព្យាបាល អ្នកដឹងច្បាស់ណាស់ថាភាគច្រើននៃសិស្សានុសិស្សរបស់យើងកំពុងជួបការលំបាកផ្នែកសង្គម ផ្លូវចិត្ត និងការសិក្សា បន្ទាប់ពីការប្រាស្រ័យទាក់ទងជាមួយគ្រូ និងមិត្តភ័ក្តិរបស់ពួកគេតាមអេក្រង់កុំព្យូទ័រអស់រយៈពេលជិតមួយឆ្នាំរួចមក។ ការបញ្ជូនកូនៗរបស់យើងដោយសុវត្ថិភាពទៅកាន់សាលារៀនរបស់ពួកគេវិញតាមដំណាក់កាលគឺជាជំហានមួយដ៏សំខាន់ក្នុងការជួយស្តារឡើងវិញនូវភាពជាសហគមន៍ និងការផ្សារភ្ជាប់ការទំនាក់ទំនង ដែលសិស្សភាគច្រើនរបស់យើងចង់បាន និងត្រូវការ។

ពេលនេះ ដោយមានវិធានការសុវត្ថិភាពយ៉ាងទូលំទូលាយដែលត្រូវបានដាក់ចេញនោះ ខ្ញុំជឿជាក់យ៉ាងមុតមាំថាសាលារៀនរបស់យើងបានត្រៀមលក្ខណៈរួចរាល់ក្នុងការស្វាគមន៍បុគ្គលិក និងសិស្សានុសិស្សឲ្យត្រឡប់មកសិក្សាដោយផ្ទាល់នៅក្នុងថ្នាក់វិញ។

ចាប់តាំងពីខែមីនាមក បុគ្គលិករាប់ពាន់នាក់របស់មណ្ឌលសិក្សាធិការបានធ្វើការនៅក្នុងសាលារៀនដើម្បីត្រៀមរៀបចំពួកគេសម្រាប់ការសិក្សាដោយផ្ទាល់នៅក្នុងថ្នាក់ប្រកបដោយសុវត្ថិភាព។

- យើងបានប្រកាសផែនការធ្វើតេស្តរហ័សសម្រាប់សិស្ស និងបុគ្គលិក ហើយការចាប់ផ្តើមនៃការមានវ៉ាក់សាំង COVID-19 សម្រាប់ផ្តល់ជូនគ្រូបង្រៀន និងបុគ្គលិកដទៃទៀត ជាកម្រិតសុវត្ថិភាពចំនួនពីរកម្រិតបន្ថែមទៀតនៅក្នុងផែនការសុខភាព និងសុវត្ថិភាពច្រើនកម្រិតរបស់យើង។

- យើងបានវិនិយោគទឹកប្រាក់ចំនួន 65 លានដុល្លារទៅលើឧបករណ៍ការពារផ្ទាល់ខ្លួនសម្រាប់សិស្ស និងបុគ្គលិក កន្លែងសម្អាតដែលសម្លាប់មេរោគដែលមិនចាំបាច់ប៉ះផ្ទាល់ របាំងប្លាស្ទិកថ្លាក្រាស់ ការជួសជុល និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធបន្សុទ្ធខ្យល់ ដើម្បីឲ្យមានលំហូរខ្យល់បរិសុទ្ធ ស្លាកសញ្ញាប្រាប់ពីការរក្សាគម្លាតសង្គម និងកម្រិតផ្សេងៗទៀត នៃសុវត្ថិភាពដែលត្រូវបានទទួលស្គាល់ ដើម្បីរក្សាការចម្លងវីរុសនៅក្នុងសាលារៀនឲ្យស្ថិតនៅក្នុងកម្រិតទាប។ នោះជាចំនួនទឹកប្រាក់ដែលបន្ថែមពីលើទឹកប្រាក់ចំនួន 250 លានដុល្លារដើម្បីដោះស្រាយបញ្ហាសារធាតុសំណ និងអាបេស្តូស និងធ្វើឲ្យប្រសើរឡើងផ្សេងៗទៀត។

ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថាខ្ញុំនឹងបន្តធ្វើការដោយមានការសហការដើម្បីស្វែងរក មូលដ្ឋានរួមមួយ ដើម្បីឲ្យយើងអាចបើកសាលារៀនប្រកបដោយសុវត្ថិភាពបានច្រើន និងឆាប់រហ័សតាមដែលអាចធ្វើបាន និងជួយសិស្សានុសិស្ស និងក្រុមគ្រួសាររបស់យើងឲ្យឆ្លងផុតពីផលប៉ះពាល់ដ៏គួរឲ្យសោកសង្រេងជាច្រើននៃជំងឺរាតត្បាតនេះ។

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.

ស្នងការ

មណ្ឌលសិក្សាធិការនៃក្រុង Philadelphia